**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ :** ១៧៣៣..................**ក.ប/ប្រ.ក**

# ប្រកាស

# ស្តីពី

# ការកែសម្រួលប្រការ៨ និងប្រការ១០ នៃប្រកាសលេខ១០៩ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ

## ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៤ នៃរដ្ឋសភា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៥២ អនក្រ/បក ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ/បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- បានឃើញប្រកាសលេខ ១០៩ កប/ប្រក ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ
- បានឃើញប្រកាសលេខ១៥០កប.ប្រក ចុះថ្ងៃទី ១៥ខែមិថុនា ឆ្នាំ២០១០ ស្តីពីការកែសម្រួល ប្រការ ៧ និងប្រការ៩ នៃប្រកាសលេខ១០៩កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ
- យោងតាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម

## សម្រេច

**ប្រការមួយ**-.

ប្រការ ៨ និងប្រការ ១០ នៃប្រកាសលេខ ១០៩កប/ប្រក ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតារកាលិកហានិភ័យការងារត្រូវបានកែសម្រួលដូចតទៅ:

**ប្រការ៨ថ្មី -.ការផ្តល់តាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍**

៨.១ កម្មករនិយោជិត ដែលទទួលរងហានិភ័យការងារ បណ្តាលឲ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍តិចជាង២០ភាគរយ មានសិទ្ធិទទួលបានប្រាក់វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារ។ ប្រាក់វិភាជន៍នេះត្រូវផ្តល់ជូនជនរងគ្រោះតែម្តងគត់ ដោយគិតតាមរូបមន្តដូចខាងក្រោម៖

វបក = បឈម x កបក x ២០% មតប

- វបក: វិភាជន៍បាត់បង់សមត្ថភាពការងារ
- បឈម: ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់ជនរងគ្រោះ
- កបក: កម្រិតបាត់បង់សមត្ថភាពការងាររបស់ជនរងគ្រោះ
- មតប: មេគុណតម្លៃបច្ចុប្បន្ន

៨.២ កម្មករនិយោជិតដែលទទួលរងហានិភ័យការងារ បណ្តាលឲ្យបាត់បង់សមត្ថភាពការងារចាប់ពី២០ភាគរយឡើង មានសិទ្ធិទទួលបានធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍។ ប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ត្រូវបានគិតតាមរូបមន្តដូចខាងក្រោម៖

ធល = បឈម x [កបក-១/៥កបក]

ធល: ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារ

៨.៣ ប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ត្រូវចាត់ទុកជាបណ្តោះអាសន្នជានិច្ច ។ បេឡាជាតិរបបសន្តិសុខសង្គម ត្រូវរៀបចំឲ្យមានការពិនិត្យសុខភាព និងសមត្ថភាពការងារ អ្នករងគ្រោះឡើងវិញក្នុងរយៈពេល១(មួយ) ឆ្នាំយ៉ាងយូរ ។ ជនរងគ្រោះដែលទទួលបានធនលាភត្រូវមានកាតព្វកិច្ចមកពិនិត្យសុខភាព តាមការកំណត់របស់ បេឡាជាតិរបបសន្តិសុខសង្គម។

៨.៤ ប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ត្រូវបានពិនិត្យឡើងវិញជារៀងរាល់ឆ្នាំ ដោយអនុលោមតាមអត្រាអតិផរណា ដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៨.៥ កម្រិតនៃការបាត់បង់សមត្ថភាពការងារ ត្រូវបានកំណត់នៅក្នុង ឧបសម្ព័ន្ធ ២ នៃប្រកាសលេខ ១០៩ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ ។

៨.៦ មេគុណតម្លៃបច្ចុប្បន្ន ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធ ៣ នៃប្រកាសលេខ ១០៩កប/ប្រក ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតារាកាលិកហានិភ័យការងារ។

**ប្រការ១០ ថ្មី-. ប្រាក់វិភាជន៍ជាសោហ៊ុយបូជាសព**

ក្នុងករណីដែលទទួលរងហានិភ័យការងាររហូតបណ្តាលឲ្យបាត់បង់ជីវិត អ្នកទទួលរ៉ាប់រងក្នុងការចាត់ចែងបូជាសព ត្រូវបានផ្តល់ប្រាក់វិភាជន៍ជាសោហ៊ុយបូជាសព ដែលមានចំនួន ៤.០០០.០០០ (បួនលាន) រៀល។ ប្រាក់វិភាជន៍នេះត្រូវតែផ្តល់ជូនទៅជនដែលទទួលបន្ទុកផ្ទាល់ក្នុងការចាត់ចែងបូជាសពជនរងគ្រោះ ។

**ប្រការពីរ-.**

ប្រកាសនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១

**រដ្ឋមន្ត្រី**

**វង សុត**

ចម្លងជូនៈ

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- ឯកសារ និងកាលប្បវត្តិ